រាជបណ្ឌិត្យសភាកម្ពុជា

# អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម

Khmer Literature In Buddhism

ភាគ នាខ

និក្ខេបបទបណ្ឌិត អក្សរសាស្ត្រ

ឯកទេស៖ អក្សរសិល្ប៍

ព.ស.២៥៥៩, ឆ្នាំ២០១៥

រាជបណ្ឌិត្យសភាកម្ពុជា

# អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម

## Khmer Literature In Buddhism

**ភាជ ណាង**

**និក្ខេបបទបណ្ឌិត អក្សរសាស្ត្រ**
**ឯកទេស៖ អក្សរសិល្ប៍**

**សាស្ត្រាចារ្យណែនាំ: បណ្ឌិតសភាចារ្យ សោម សុមុនី**
**សាស្ត្រាចារ្យណែនាំរង: បណ្ឌិតសភាចារ្យ ស៊ុំ ឈុំប៊ុន**

ព.ស.២៥៥៩, ឆ្នាំ២០១៥

# មាតិកា


ទំព័រ

- មាតិកា ....................................................... i
- ឧទ្ទិសស្នាដៃ ....................................................... iv
- សេចក្តីថ្លែងអំណរគុណ ....................................................... v
- អំណះអំណាង ....................................................... vi
- អក្សរកាត់(ប្រើក្នុងនិក្ខេបបទ) ....................................................... vii
- មូលន័យសង្ខេប ....................................................... viii
- Abstract ....................................................... ix
- សង្ខេបនិក្ខេបបទ ....................................................... x
- អារម្ភកថា ....................................................... xi

## សេចក្តីផ្តើម

១- លំនាំបញ្ហានៃការស្រាវជ្រាវ ....................................................... ១
២- ចំណោទបញ្ហានៃការស្រាវជ្រាវ ....................................................... ៣
៣- គោលបំណងនៃការស្រាវជ្រាវ ....................................................... ៣
៤- ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ....................................................... ៤
៥- វិធីសាស្ត្រនៃការស្រាវជ្រាវ ....................................................... ៤
៦- សារៈប្រយោជន៍នៃការស្រាវជ្រាវ ....................................................... ៥
៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....................................................... ៦

## ជំពូក១
## ទស្សនាទានស្តីពីអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម

១.១-ទស្សនៈទូទៅនៃអក្សរសិល្ប៍ ....................................................... ៧
១.១.១-បញ្ញត្តិអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម ....................................................... ៨
១.១.២-និយមន័យអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម ....................................................... ១២
១.១.៣-លក្ខណៈផ្សេងៗនៃអក្សរសិល្ប៍ពុទ្ធនិយមក្នុងប្រទេសនានា ....................................................... ១៤
១.២- ប្រភពអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម ....................................................... ១៧
១.២.១- ប្រភពស្នាដៃទសជាតក ....................................................... ១៧
១.២.២- ប្រភពស្នាដៃបញ្ញាសជាតក ....................................................... ១៩
១.២.៣- ប្រភពអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ ....................................................... ២២
១.៣- ឥទ្ធិពលបដិការរវាងអក្សរសិល្ប៍និងសង្គម ....................................................... ២៣

១.៣.១- អក្សរសិល្ប៍កំណត់ដោយសង្គមបរិយាកាលនិងសម័យកាលសង្គម .... ២៣
១.៣.២- អក្សរសិល្ប៍មានឥទ្ធិពលទៅលើសម័យកាលនិងសង្គម .......... ២៣

## ជំពូក២
## វិវត្តភាពទូទៅនៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម

២.១- ស្ថានភាពសង្គមវប្បធម៌ខ្មែរសម័យកាលកើតអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម .. ២៥
២.១.១- ការទទួលយកនៃពុទ្ធសាសនាថេរវាទ .......... ២៨
២.១.២- ស្ថានភាពអ្នកនិពន្ធ .......... ៣២
២.១.៣- ស្ថានភាពនៃការផ្សព្វផ្សាយអក្សរសិល្ប៍ .......... ៣៤
២.២- ស្ថានភាពវិវត្តន៍នៃអក្សរសិល្ប៍ខ្មែរពីព្រាហ្មណ៍និយមមកពុទ្ធនិយម .......... ៣៩
២.២.១- សម័យកាលវិវត្តន៍ .......... ៤៧
២.២.២- វិវត្តន៍វិធីសាស្ត្រតែងនិពន្ធ .......... ៤៩
២.២.៣- វិវត្តន៍និទ្ទាការស្មោដៃ .......... ៥១
២.៣- ប្រភេទអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម .......... ៥៤
២.៣.១- អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ .......... ៥៥
២.៣.២- អក្សរសិល្ប៍ពុទ្ធនិយមក្លាយ .......... ៨៩
២.៣.៣- អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ .......... ៩៩
២.៣.៤- នានាជាតក .......... ១១៤

## ជំពូក៣
## វិចយការណ៍លើអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម

៣.១- លក្ខណៈរួមនៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម .......... ១២៩
៣.១.១- កាលអាកាស .......... ១២៩
៣.១.២- ការបង្ហាញតួអង្គ .......... ១៣៣
៣.១.៣- គោលដៅរបស់អ្នកនិពន្ធ(គំនិតដឹកនាំរឿង) .......... ១៣៦
៣.២- ឥទ្ធិពលអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមលើសង្គមវប្បធម៌ .......... ១៣៨
៣.២.១- ឥទ្ធិពលលើវិស័យហោរាសាស្ត្រ .......... ១៣៨
៣.២.២- ឥទ្ធិពលលើវិស័យសិល្បៈ .......... ១៤៣
៣.២.៣- ឥទ្ធិពលលើវិស័យតុលាការ .......... ១៤៨
៣.២.៤- ឥទ្ធិពលលើវិស័យនយោបាយ .......... ១៥១
៣.២.៥- ឥទ្ធិពលលើវិស័យច្បាប់ .......... ១៦១
៣.៣- តម្លៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមក្នុងសង្គម .......... ១៦៦

៣.៣.១- តម្លៃក្នុងការបណ្ដុះបញ្ញា ............................................................ ១៦៩
៣.៣.២- តម្លៃបណ្ដុះស្មារតីមនុស្សឱ្យចេះដឹងគុណនិងការជឿលើកម្លាំងខ្លួន .... ១៧៤
៣.៣.៣- តម្លៃបណ្ដុះស្មារតីឱ្យមនុស្សជឿលើអំពើបុណ្យនិងបាប .................. ១៧៧
៣.៣.៤- តម្លៃបណ្ដុះស្មារតីសន្តិភាព ............................................................ ១៨០

**សេចក្ដីសន្និដ្ឋាន** ............................................................ ១៨៣
**គន្ថនិទ្ទេស** ............................................................ ១៨៦
**ឧបសម្ព័ន្ធ**

# មូលន័យសង្ខេប

ការចំរើនរុងរឿងនៃលទ្ធិព្រហ្មញ្ញសាសនាក្នុងសម័យអង្គរ និង ប្រទេសជួបវិបត្តិដោយសារសង្គ្រាមផងនោះ ជាកត្តាមួយនាំឱ្យប្រជាពលរដ្ឋខ្មែរទទួលយកព្រះពុទ្ធសាសនាថេរវាទសាឡើងវិញ ដែលជាសាសនាប្រកបដោយហេតុផល មកគោរពនៅសម័យកណ្ដាល។ ពុទ្ធសាសនាថេរវាទ ជាកំណើតដើមនៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម។ ស្នាដៃអក្សរសិល្ប៍នេះ ត្រូវបានអ្នកសិក្សាស្រាវជ្រាវកំណត់ឈ្មោះហៅប្រហាក់ប្រហែលគ្នាដូចជាថា អក្សរសាស្ត្រពុទ្ធសាសនា អក្សរសាស្ត្រពុទ្ធនិយម រឿងសាសនា អក្សរសិល្ប៍ពុទ្ធនិយម រឿងពុទ្ធនិយម ជាដើម។

អក្សរសិល្ប៍ពុទ្ធនិយមនេះ ទទួលឥទ្ធិពលពីពុទ្ធសាសនាថេរវាទ ហើយមានវិសាលភាពក្នុងប្រទេសជាច្រើននៃតំបន់អាស៊ីភាគអាគ្នេយ៍ ដូចជា ប្រទេសខ្មែរ លាវ ថៃ ភូមា ជាដើម។ ស្នាដៃទាំងនេះ មានប្រភពដើមពីគម្ពីរព្រះត្រៃបិដក ពិសេសក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ហើយត្រូវបានអ្នកនិពន្ធក្នុងប្រទេសនីមួយៗ កែច្នៃឱ្យស្របទៅតាមទស្សនៈគំនិតប្រពៃណីទំនៀមទម្លាប់រស់នៅរបស់ប្រទេសខ្លួន ដោយរក្សានូវខ្លឹមសារដើម និង រឿងមួយចំនួនទៀតត្រូវបានអ្នកនិពន្ធតាក់តែងរចនាថ្មីឡើង ដោយបញ្ចេញបញ្ចូលដំណើររឿងទៅតាមការយល់ឃើញរបស់ខ្លួន តែឈរលើមូលដ្ឋានទ្រឹស្ដីពុទ្ធសាសនា ជាចាំបាច់។

ឯស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម ដែលកើតនៅក្នុងសម័យលង្វែកនិងឧដុង្គ ក៏សុទ្ធតែទទួលឥទ្ធិពលពុទ្ធសាសនាថេរវាទយ៉ាងជ្រាលជ្រៅ ហើយបានរីកចម្រើនយ៉ាងខ្លាំងក្នុងសតវត្សទី១៨-១៩ នៃប្រវត្តិអក្សរសិល្ប៍របស់ខ្មែរ។ ឯប្រធានបទដែលអ្នកនិពន្ធជ្រើសយកមកសរសេរក្នុងស្នាដៃរបស់ខ្លួន គឺទាក់នឹងការបំពេញបារមីរបស់ព្រះពោធិសត្វដើម្បីបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ទាក់នឹងការធ្វើទាន ទាក់នឹងការកសាងអំពើជាកុសលផ្សេងៗរបស់ពោធិសត្វ ទាក់ទងនឹងកម្មពៀរ បាបនិងបុណ្យ ជាដើម។ ឯការផ្សព្វផ្សាយវប្បធម៌ អក្សរសាស្ត្រ អក្សរសិល្ប៍ និងព្រឹត្តិការណ៍សង្គមផ្សេងៗនៅសម័យនោះ គឺតាមរយៈសាស្ត្រា ដែលគេតម្កល់នៅក្នុងវត្តសម្រាប់បង្រៀនសិស្ស ក្រាំងព្រះសង្ឃទេសនា ការនិយាយរឿងប្រាប់គ្នាតៗជាដើម។ មិនតែប៉ុណ្ណោះ សិស្សដែលចូលរៀនក្នុងសាលាវត្ត ក្រោយពីទទួលបានចំណេះដឹងពីព្រះសង្ឃសព្វសារពើហើយ ពួកគេត្រូវចារសាស្ត្រា ហើយចែកជូនតាមវត្តអារាមដែលត្រូវការ ដើម្បីឱ្យអ្នកសិក្សានៅសាលាវត្តក្រោយៗទៀតបានរៀនសូត្រ។ រាល់ខ្លឹមសារក្នុងស្នាដៃនីមួយៗពោរពេញទៅដោយការអប់រំឱ្យមនុស្សប្រព្រឹត្តនូវអំពើល្អ បណ្ដុះស្មារតីអហិង្សា ក្នុងការប្រាស្រ័យទាក់ទងនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ស្នាដៃទាំងនេះ ទទួលបាននូវការពេញនិយមពីសំណាក់ប្រជាពលរដ្ឋខ្មែរទាំងក្នុងសម័យមុននិងសម័យបច្ចុប្បន្ន ហើយមានឥទ្ធិពលយ៉ាងជ្រៅទៅលើសង្គមវប្បធម៌ខ្មែរ ដូចជា ក្នុងវិស័យហោរាសាស្ត្រ វិស័យសិល្បៈ វិស័យតុលាការ វិស័យ នយោបាយ វិស័យច្បាប់ ។ល។

សរុបមក អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម នៅសម័យកណ្ដាល ជាស្នាដៃយ៉ាងសំខាន់បំផុតក្នុងការរួមចំណែកអភិវឌ្ឍមរតកវប្បធម៌ អក្សរសាស្ត្រ អក្សរសិល្ប៍ឱ្យរីកចម្រើន និងជាខឿនដ៏រឹងមាំរបស់វប្បធម៌អរិយធម៌ខ្មែរ។

# ABSTRACT

Due to the falling down of Hinduism in the Angkor Period and the country faced the war with near-boring country caused Khmer citizen to receive Theravada Buddhism which is a rational religion to practice in the middle age. The Theravada Buddhism was the origin of Khmer Buddhist literature. The work of Buddhist literature has been determined the similarity as the literature of Buddhist religion, literature of Buddhism, religious stories, Buddhist stories etc.

This Buddhist literature is influenced from Buddhism and to be propagated comprehensively in many countries in the Southeast Asia such as Cambodia, Loa, Thailand and Burma and so on. These works were derived from the Buddhist canon, especially in the Sutta Pitaka (discourses) of Khuddaka Nikâya Jataka( Birth stories of the Bodhisatta ) and were revised by each countries' authors in accordance with their perspectives, customs, traditions by maintaining the original forms and some story were re-composed and re-written by including the process of the stories in accordance with their understanding, but basing on the foundation of Buddhist teachings necessarily.

The works, however, of Khmer Literature in Buddhist that appeared in the period of Long Vek and Udong were comprehensively full of Theravada Buddhist influences in the $18^{th}$-$19^{th}$ century of the history of Khmer literature. To the topics were chosen to write by the authors for their works were related to the performing of Bodhisatta's perfections in order to attain enlightenment as the Buddha, but some performing of the perfections, such as charity and so on were only concerning with cause and effect and virtuous things.While, the propagation of culture, literature and social events at that times were through Satra(documents written on palm leaves) keeping on the monasteries for teachings students, scroll or documents( ancient parchment book folded into section) for monks preaching, telling from one to one person etc. Moreover, students who enrolled to study at school of monasteries (Pagoda school) were well educated from the Buddhist monks, they wrote, recorded these works and distributed to other monasteries needed for the next students to study. All meanings and essences of each works were full of educations, personal growth, building non-violence spirits in communication with daily lives. These works received the prestige, popularity of the former and present Khmer citizen and influenced deeply on the cultural sociology such as the aspect of astrology, arts, court, politics and law so on.

In short, Khmer Literature in Buddhist in the middle age were the most important works in developing cultural heritages, literature in progressive and the strong pillar of Khmer civilization.

# សង្ខេបនិក្ខេបបទ

ព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនាមានប្រភពពីប្រទេសឥណ្ឌា។ សាសនាទាំងពីរនេះជាធាតុដ៏សំខាន់ក្នុងការបង្កើតវប្បធម៌របស់ខ្មែរ។ បុព្វបុរសរបស់ខ្មែរបានយកសាសនាទាំងនេះល្បាយជាមួយវប្បធម៌ចាស់របស់ខ្លួន ច្នៃលៃឱ្យមានលក្ខណៈស្របនឹងគំនិតទស្សនៈរបស់ប្រជាពលរដ្ឋខ្មែរ ទើបប្រទេសខ្មែរទទួលបាននូវភាពរុងរឿងជាបន្តបន្ទាប់ ជាពិសេសក្នុងសម័យអង្គរនិងសម័យក្រោយទៀត។ សាសនាទាំងពីរបាននាំមកនូវភាសាសំស្ក្រឹតនិងភាសាបាលីចូលមកល្បាយជាមួយភាសាខ្មែរនៅក្នុងប្រទេសខ្មែរ។ ឥទ្ធិពលសាសនាទាំងពីរបានចាក់ឫសយ៉ាងជ្រៅលើស្មារតី ចិត្តគំនិតរបស់ប្រជាពលរដ្ឋខ្មែរ ហើយមិនតែប៉ុណ្ណោះ សាសនាទាំងពីរបាននាំមកនូវអក្សរសាស្ត្រ និង អក្សរសិល្ប៍ ដែលមានឥទ្ធិពលព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនាទៀតផង។ អក្សរសិល្ប៍ដែលលេចធ្លោជាងគេគឺរឿងរាមកេរ្តិ៍ មានឥទ្ធិពលព្រហ្មញ្ញសាសនា ដែលប្រជាជនខ្មែរចាត់ទុកជាស្នាដៃដ៏ឆ្នើមក្នុងសម័យអង្គរ។ បន្ទាប់ពីឥទ្ធិពលព្រហ្មញ្ញសាសនាបានថមថយទៅ ខ្មែរបានងាកមកគោរពព្រះពុទ្ធសាសនាសាឡើងវិញ។ ព្រះពុទ្ធសាសនានាំមកនូវអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម។ អក្សរសិល្ប៍នេះ ជាស្នាដៃដ៏សំខាន់នៃអក្សរសិល្ប៍ខ្មែរ ដែលមានតាំងពីសម័យកណ្ដាល(លង្វែកនិងឧដុង្គ) ហើយនៅតែជាទីពេញអានរបស់ប្រជាពលរដ្ឋខ្មែររហូតបច្ចុប្បន្ន។ នៅក្នុងស្នាដៃអក្សរសិល្ប៍មានចំណេះដឹងដ៏សម្បូរបែបស្ដីអំពីមនុស្ស វប្បធម៌ ទំនៀមទម្លាប់ប្រពៃណី និងរាល់ទំនាក់ទំនងមនុស្សនិងមនុស្ស។ល។ មិនតែប៉ុណ្ណោះវាឆ្លុះបញ្ចាំងនូវប្រវត្តិសាស្ត្រនិងសង្គមសាស្ត្របែមទៀតផង។ មរតកវប្បធម៌ អរិយធម៌ ទាំងអស់នេះ ស្ថិតក្នុងអារម្មណ៍របស់កូនខ្មែរគ្រប់រូប ហើយតែងតែធ្វើឱ្យយើងនឹកដល់ស្នាដៃបុព្វបុរសដ៏ឆ្នើម ដែលជាព្រលឹងជាតិ ពុំអាចបំភ្លេចបាន។ ជាងនេះទៅទៀតរឹតតែធ្វើឱ្យយើងមានចិត្តស្រឡាញ់ថែរក្សាការពារនូវសម្បត្តិវប្បធម៌ដ៏ឧត្ដុង្គឧត្ដមនេះជានិរន្តតទៅ។

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម ជាប្រលោមលោកបុរាណ ទទួលឥទ្ធិពលពុទ្ធសាសនាយ៉ាងជ្រាលជ្រៅ ដែលធ្វើឱ្យអ្នកអាន អ្នកស្ដាប់ អ្នកទស្សនា ទទួលបាននូវការអប់រំដ៏ល្អៗ បទពិសោធន៍ផ្សេងៗ និងការបណ្ដុះស្មារតីអហិង្សាឱ្យមានសន្តិភាព ព្រមទាំងផ្ដល់នូវភាពសប្បាយរីករាយចាកផុតពីសេចក្ដីទុក្ខកង្វល់នឿយណាយក្នុងជីវិតទៀតផង។ នៅក្នុងសម័យកណ្ដាលជារយៈពេលមួយដែលប្រទេសកម្ពុជាជួបប្រទះនូវវិបត្តិគ្រប់បែបយ៉ាង( សង្គ្រាមឈ្លានពានពីសំណាក់ប្រទេសជិតខាង ជម្លោះផ្ទៃក្នុង គ្រោះទុរ្ភិក្សផ្សេងៗ ជាដើម) អក្សសិល្ប៍ខ្មែរបែបពុទ្ធនិយមដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំមនុស្សឱ្យយល់ពីហេតុពិតនៃជីវិត ផ្សារភ្ជាប់នឹងការតស៊ូចំពោះបញ្ហា និង ពង្រឹងស្មារតីប្រជាជនឱ្យរឹងមាំរស់នៅក្នុងជីវភាពជាក់ស្ដែង ដើម្បីទប់ទល់ជាមួយសត្រូវឈ្លានពានបរទេសទាំងឡាយដែលប៉ុនប៉ងលេបត្របាក់ទឹកដីប្រទេសកម្ពុជា។

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម ត្រូវបានគេស្គាល់និងហៅឈ្មោះ នៅពេលដែលប្រជាជនខ្មែរគោរពព្រះពុទ្ធសាសនាថេរវាទយ៉ាងមុតមាំ និង ក្នុងពេលដែលព្រះពុទ្ធសាសនាបានរីកចម្រើននៅក្នុងប្រទេសកម្ពុជានាសម័យកណ្ដាល។ ការកំណត់ហៅឈ្មោះខាងលើនេះ ស្របពេលដែលអ្នកប្រាជ្ញខ្មែរបានទៅរៀននៅប្រទេសលង្កា នៅពេលពួកគេត្រឡប់មកប្រទេសខ្លួនវិញ ពួកគេបានបកប្រែរឿងពីភាសាបាលី មកភាសាជាតិរបស់ខ្លួន និង និពន្ធរឿងផ្សេងៗទៀតទៅតាមទស្សនៈការយល់ឃើញរបស់ខ្លួន ស្របនឹងគំនិតរបស់ខ្មែរ។ បន្ទាប់ពីនោះ អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម ទទួលបាននូវការពេញនិយមពីសំណាក់ប្រជាពលរដ្ឋខ្មែរយ៉ាងខ្លាំង ហើយមានអ្នកនិពន្ធយ៉ាងច្រើនដែលសរសេររឿងក្នុងអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមនេះ។ ព្រះសង្ឃបានយករឿងមួយចំនួននៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម ទេសនាក្នុងពិធីបុណ្យជាតិផ្សេងៗ ជាងនេះទៅទៀតនៅសម័យមុនព្រះសង្ឃបានចារលើសាស្ត្រាស្លឹករឹត ចម្លងតៗគ្នា តម្កល់ទុកក្នុងវត្តនីមួយៗសម្រាប់ព្រះសង្ឃឬសិស្សរៀនសូត្រ។ អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម ត្រូវអ្នកសិក្សាស្រាវជ្រាវហៅឈ្មោះផ្សេងៗគ្នាដូចជា៖ រឿងសាសនា អក្សរសាស្ត្រសាសនា អក្សរសាស្ត្រពុទ្ធនិយម អក្សរសិល្ប៍ពុទ្ធនិយម អក្សរសិល្ប៍ផ្នែកពុទ្ធនិយម អក្សរសាស្ត្រពុទ្ធសាសនាឬព្រះត្រៃបិដក ប្រភេទរឿងពុទ្ធនិយម ជាដើម។

ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលគោរពព្រះពុទ្ធសាសនាថេរវាទដូចជា ប្រទេសខ្មែរ ប្រទេសភូមា ប្រទេសលាវ និងប្រទេសថៃ ជាដើម សុទ្ធតែមានស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមនេះ គ្រាន់តែអ្នកនិពន្ធនៃប្រទេសនីមួយៗយកស្នាដៃទាំងនោះទៅកែច្នៃខ្លះៗ ឬយកប្រធានបទដែលទាក់ទងនឹងប្រវត្តិរបស់ព្រះសម្មាសម្ពុទ្ធ មកតាក់តែងនិពន្ធឱ្យស្របទៅតាមការនិយមចូលចិត្ត និងឱ្យស្របតាមប្រពៃណីទំនៀមទម្លាប់របស់ប្រទេសរៀងៗខ្លួន។

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម មានប្រភពដំបូងចេញពីគម្ពីរព្រះត្រៃបិដក( សុត្តន្តបិដក ខុទ្ទកនិកាយជាតក) ហើយមានវត្តមាននៅលើទឹកដីខ្មែរក្នុងសម័យកណ្ដាល( លង្វែកនិងឧដុង្គ, ស.វ.ទី១៥-១៩) ពេលដែលខ្មែរយើងគោរពពុទ្ធសាសនាថេរវាទយ៉ាងមុតមាំ។ មូលហេតុសំខាន់ដែលខ្មែរទទួលយកព្រះពុទ្ធសាសនាថេរវាទគឺ ដោយពុទ្ធសាសនា ផ្អែកលើគោលការណ៍សត្យានុម័ត ស្របទៅតាមចរិតរបស់ខ្មែរ វប្បធម៌ខ្មែរ ស្របតាមភូមិសាស្ត្រសាសនា, ផ្អែកលើសច្ចធម៌។ ការប្រៀនប្រដៅរបស់ពុទ្ធសាសនា ជាមាគ៌ាដ៏សំខាន់ក្នុងដំណើរការអភិបាលកិច្ច សង្គមកិច្ច និងនីតិរដ្ឋ គឺផ្សារភ្ជាប់បានគ្រប់វិស័យទាំងអស់នៃជីវិតក្នុងសង្គម។ មិនតែប៉ុណ្ណោះរាល់ការអប់រំរបស់ពុទ្ធសាសនាប្រកបដោយភាពអហិង្សា សន្តិភាព និងជាទ្រឹស្ដីលោកសម្រាប់មនុស្សជាតិ មិនប្រកាន់វណ្ណៈ ពណ៌សម្បុរ មានក្រអឺទ្បើយ។

ការសិក្សារៀនសូត្ររបស់ខ្មែរសម័យនោះ គឺពឹងផ្អែកលើទីវត្តអារាម ព្រោះវត្តអារាមជាសាលារៀនសម្រាប់បណ្ដុះបណ្ដាលចំណេះវិជ្ជាគ្រប់ប្រភេទដល់កូនខ្មែរគ្រប់រូប។ ព្រះសង្ឃមានតួនាទីយ៉ាងសំខាន់ក្នុងការបង្ហាត់បង្រៀននូវរាល់ចំណេះដឹងទាំងឡាយ ដូចជា បង្រៀនលេខ

អក្សរសាស្ត្រ វិជ្ជាពេទ្យ ច្បាប់សីលធម៌ ការរចនា និង វិជ្ជាជីវៈផ្សេងៗ ពិសេសទៀតនោះគឺចំណេះដឹងខាងពុទ្ធសាសនា។ ដោយសារតែនៅទីវត្តអារាមជាមជ្ឈមណ្ឌលផ្តល់នូវចំណេះបែបនេះហើយ ទើបគ្រួសារនីមួយៗនៅសម័យនោះបញ្ជូនកូនចៅមកវត្តអារាមដើម្បីសិក្សារៀនសូត្រ។ ព្រះសង្ឃនិងសិស្សសាលាវត្តនេះហើយ ជាអ្នកផលិតសាស្ត្រា និងក្រាំងផ្សេងៗចែកជូនទៅគ្រប់វត្តអារាមក្នុងប្រទេសកម្ពុជា សម្រាប់សិស្សបានសិក្សាក្នុងសម័យនោះ។

អក្សរសិល្ប៍ខ្មែរមានការវិវត្តន៍តាមសម័យកាលធំៗនៃប្រវត្តិសាស្ត្រ, ការប្រែប្រួលនៃរបបដឹកនាំសង្គម និង ការផ្លាស់ប្តូរជំនឿសាសនារបស់ខ្មែរក្នុងសម័យកាលនីមួយៗ។ នៅសម័យអង្គរវប្បធម៌អរិយធម៌ខ្មែរឡើងដល់កម្រិតកំពូល រីឯអក្សរសិល្ប៍ក៏រីកចម្រើនខ្លាំងណាស់ដែរ ប៉ុន្តែថមថយវិញនៅពេលដែលប្រទេសខ្មែរត្រូវបរទេសឈ្លានពាន។ អក្សរសិល្ប៍នៅសម័យអង្គរ ពិតមែនតែបានទទួលឥទ្ធិពលនៃលទ្ធិវេទ លទ្ធិព្រាហ្មណ៍ និង ពុទ្ធសាសនាជាបន្តបន្ទាប់ តែនៅតែរក្សាលក្ខណៈជាខ្មែរ ក្នុងនោះយើងឃើញមានស្នាដៃរឿង*រាមកេរ្តិ៍* អ្នកនិពន្ធសរសេរជាពាក្យកាព្យ មានទំនោរទៅរកព្រហ្មញ្ញសាសនា ដែលខ្មែរគោរពនៅសម័យនោះ។ អក្សរសិល្ប៍ខ្មែរបន្ទាប់ពីរីកចម្រើន ក៏ស្រាប់តែត្រឡប់ជាសូន្យឈឹងក្នុងរវាងសតវត្សទី១៥-១៦ ដោយសារសភាពអាប់អួនៃប្រវត្តិសាស្ត្រ ដែលបង្កដោយពួកសត្រូវបរទេសឈ្លានពានប្រទេសខ្មែរ។ លុះមកដល់សតវត្សទី១៧ ស្នាដៃអក្សរសិល្ប៍បានងើបឡើងវិញ ឯភាសាបាលីដែលប្រើក្នុងព្រះពុទ្ធសាសនាថេរវាទ បានចូលមកជំនួសភាសាសំស្ក្រឹត ទុកជាភាសាអ្នកប្រាជ្ញវិញម្តង ហើយទស្សនៈពុទ្ធសាសនានិងអក្សរសិល្ប៍ក៏កាន់តែជ្រួតជ្រាបយ៉ាងឆាប់ហ័សក្នុងសន្តានចិត្តរបស់ប្រជារាស្ត្រខ្មែរ។ នៅក្នុងសម័យនោះ មានស្នាដៃអក្សរសិល្ប៍សាមញ្ញកើតឡើង ដូចជារឿងព្រេង រឿងនិទានខ្លីៗ ដែលនាំឱ្យអ្នកស្រុកស្តាប់និងយល់បានយ៉ាងងាយ។

នៅរវាងសតវត្សទី១៨-១៩ ដោយសារការរើករវចលាចលក្នុងស្រុកផង និងដោយសារសង្គ្រាមឈ្លានពានពីបរទេសផង ការផ្សព្វផ្សាយស្នាដៃអក្សរសិល្ប៍ពុំបានរីកសាយភាយទូលំទូលាយឡើយ។ ម្យ៉ាងទៀត ដោយសារវិធីតែងពាក្យកាព្យឬពាក្យរាយគ្មានឯកភាពគ្នា ទើបក្រុមអ្នកចេះដឹងខ្មែរយើងបានកែស្ថានភាពថមថយនេះឡើងវិញ ដូចជា បានរៀបចំឱ្យមានក្បួនខ្នាតតែងកាព្យនិងរបៀបសរសេរពាក្យរាយឱ្យបានត្រឹមត្រូវ ចាត់ចែងឱ្យមានការរៀនភាសាបាលីយ៉ាងជ្រាលជ្រៅ ចាត់ចែងឱ្យបកប្រែគម្ពីរខាងព្រះពុទ្ធសាសនា និងរឿងជាតកជាភាសាបាលី មកជាភាសាខ្មែរ។ ក្រោយពីស្នាដៃទាំងនោះសម្រួលបានសមរម្យហើយ ទើបនាំឱ្យអ្នកស្រុកងាយយល់ងាយចាំក្នុងការអាន ហើយនិយាយតមាត់ពីកន្លែងទៅកន្លែងមួយ រហូតដល់រឿងរ៉ាវទាំងនោះក្លាយទៅជារឿងអក្សរសិល្ប៍ពេញនិយមសម្រាប់អ្នកស្រុកទូទៅ។ បន្ទាប់មកស្នាដៃអក្សរសិល្ប៍មួយចំនួន ពិសេសស្នាដៃជាប្រលោមលោកពាក្យកាព្យដែលមានបង្កប់នូវទស្សនៈព្រះពុទ្ធសាសនាក៏មានកំណើតឡើង។ គេចាររឿងរ៉ាវទាំងនោះ លើស្លឹករឹត ហើយគេចម្លងតៗគ្នា ចែកគ្នាអានសុសសាយពេញទាំងស្រុកភូមិ។

អ្នកនិពន្ធដែលគេស្គាល់ច្បាស់លាស់នោះមាន៖ ឧកញ៉ាកោសាធិបតីកៅ សរសេររឿងក្រុងសុភមិត្រ, ឧកញ៉ាព្រះឃ្លាំងនង សរសេរច្បាប់សុភាសិត រឿងលោកនេយ្យជាតក រឿងបុញ្ញសាសិរិសោ រឿងភោគកុលកុមារ, ឧកញ៉ាសន្ធរពោហារម៉ុក សរសេររឿងទេវន្ទ ល្បើកចចក រឿងទុំទាវ(មុនរឿងទុំទាវរបស់ភិក្ខុសោម), វិសេសផុង សរសេរល្បើកអក ល្បើកផុចនិងត្រី ល្បើកផ្ទំដក, ព្រះអង្គឌួង សរសេរចម្បាំងចោង រឿងកាកី ច្បាប់ស្រី និងរឿងព្រះមហាវេស្សន្តរ(ពាក្យកាយ)។ល។

ស្នាដៃទាំងឡាយដែលយើងរកឃើញ ហើយបញ្ជាក់ថាជាស្នាដៃសម័យកណ្តាលនោះ មានតែស្នាដៃក្នុងសតវត្សទី១៧-១៩ តែប៉ុណ្ណោះ។ ក្រុមអ្នកសិក្សាច្រើនកំណត់ព្រមៗគ្នាថា សតវត្សទី១៧ ជាសម័យកំណើតថ្មីនៃអក្សរសិល្ប៍ខ្មែរ។ បើពិនិត្យស្នាដៃទាំងឡាយ យើងឃើញថា ក្នុងសម័យកំណើតថ្មីនោះ អក្សរសិល្ប៍ខ្មែរបានវិវត្តន៍មួយជំហានថ្មី ទាំងខាងវិធីសាស្រ្តតែងនិពន្ធនិងទាំងគោលនិយមស្នាដៃ។ ការវិវត្តន៍នេះ ទាក់ទងទាំងស្រុងដល់ឥទ្ធិពលសាសនា ដែលខ្មែរឈប់គោរព គឺព្រហ្មញ្ញសាសនា និង ពុទ្ធសាសនាមហាយាន ហើយទៅគោរពពុទ្ធសាសនាថេរវាទសាឡើងវិញ។ ពុទ្ធសាសនាថេរវាទសម័យកាលនោះ រីកចម្រើនលូតលាស់យ៉ាងខ្លាំង ហើយមានឥទ្ធិពលលើជីវភាពសង្គមទាំងមូល ព្រមទាំងលើនិម្មិតកម្មអក្សរសិល្ប៍ទៀតផង។ ក្នុងមជ្ឈដ្ឋានអ្នកសិក្សា គេបានជ្រើសរើសយកភាសាបាលី ដែលប្រើក្នុងគម្ពីរពុទ្ធសាសនាថេរវាទ ហើយបោះបង់ចោលភាសាសំស្ក្រឹតនៃព្រហ្មញ្ញសាសនា។ កវីខ្មែរសម័យនោះ បានរចនាពាក្យពេចន៍បាលីលាយខ្មែរឱ្យក្លាយជាឃ្លាកាព្យ និង ស្នាដៃជាពាក្យកាព្យយ៉ាងពីរោះរណ្តំ។ យើងសង្កេតឃើញថា ឃ្លាកាព្យបាលី-ខ្មែរ សម័យនោះមានលក្ខណៈអណ្តែតអណ្តូងបម្រើឱ្យបទរីណាកថា ផ្ទុយទាំងស្រុងពីឃ្លាកាព្យសំស្ក្រឹត-ខ្មែរនាសម័យអង្គរ ដែលស្របនឹងខ្លឹមសារកេរ្តិ៍ថា។

សម័យកណ្តាល ជាពេលដែលអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមបានចាប់កំណើតឡើងយ៉ាងជាក់លាក់ វាទាក់ទងនឹងកត្តាសង្គមធ្លាក់ចុះដែលមានស្ថានភាពវឹកវរ ប្រជាជនជួបការលំបាក និងជាពិសេសទាក់ទងនឹងការទទួលយកព្រះពុទ្ធសាសនាថេរវាទ។ ពុទ្ធសាសនាថេរវាទ បានអប់រំមនុស្សឱ្យជឿលើទស្សនៈកម្មផល ហើយមិនតែប៉ុណ្ណោះសាសនានេះ ជាឫសកែវនាំឱ្យកើតមានកវីបណ្ឌិតផ្នែកអក្សរសាស្រ្តអក្សរសិល្ប៍ក្នុងសម័យកណ្តាល ពិសេសសម័យឧដុង្គ ដែលបន្សល់ស្នាដៃទុករហូតបច្ចុប្បន្ន។ ក្នុងប្រវត្តិអក្សរសិល្ប៍ខ្មែរ យើងឃើញក្នុងសម័យកណ្តាលនេះ មានវិវត្តន៍ខាងវិធីសាស្រ្តពីដំណាក់កាលផ្សេងៗគ្នា ៖

-ក្នុងដំណាក់កាលដំបូង គឺសតវត្សទី១៦-១៧ យើងឃើញមានតែអត្ថបទពាក្យកាយសម្រាប់ទេសនា ពាក្យកាព្យ បែបរឿងនិទាន និង អត្ថបទកំណាព្យ បែបមនោសញ្ចេតនាតែប៉ុណ្ណោះ។ កវីសំខាន់ៗនៃដំណាក់កាលនោះមាន ៖

ក្រុមអ្នកនិពន្ធខ្មែរ សរសេរបញ្ញាសជាតក ជាពាក្យកាយ នៅអំឡុងឆ្នាំ១៤៥៧-១៦៥៧

អ្នកប៉ង សរសេររឿងល្បើក ជាពាក្យកាព្យ ឈ្មោះ «*ល្បើកអង្គរ*» នៅឆ្នាំ១៦០៩ និទាន រៀបរាប់ពីរឿងរ៉ាវ ដែលនាំឱ្យមានការកសាងប្រាសាទអង្គរ។

ព្រះរាជសម្ភារ សរសេរកំណាព្យមនោសញ្ចេតនា៖ កំណាព្យ«*ហេមន្តមាស*»១៦២៩, កំណាព្យ «*កាព្យនិរាស*» ឆ្នាំ១៦៦០។

កំណាព្យព្រះរាជសម្ភារ ជាអត្ថបទកំណាព្យដែលលាតត្រដាងតែអំពីមនោសញ្ចេតនា កម្ចោស់អត្ថបទចំពោះនារី និងធម្មជាតិ ដែលលោកស្រឡាញ់តែប៉ុណ្ណោះ។

-ដំណាក់កាលទី២ គឺចាប់ពីសតវត្សទី១៨ ទើបយើងឃើញមានការតាក់តែងស្នាដៃបែបប្រលោមលោកជាពាក្យកាព្យ។ ជាទូទៅយើងឃើញថា និម្មិតកម្មអក្សរសិល្ប៍សម័យនោះស្ថិតទាំងស្រុងលើមូលដ្ឋានគម្ពីរពុទ្ធសាសនា ជាពិសេសគម្ពីរសុត្តន្តបិដក ខុទ្ទកនិកាយជាតកមហានិបាត(ព្រះត្រៃបិដក) និងគម្ពីរបញ្ញាសជាតក បានក្លាយជាប្រភពនៃនិម្មិតកម្មចំណងជើងរឿង និងនិម្មិតកម្មដំណើររឿងជាច្រើនរបស់អ្នកនិពន្ធខ្មែរ។ ក្នុងអំឡុងសតវត្សទី១៨-១៩ អ្នកនិពន្ធខ្មែរខ្លះបានដកស្រង់យករឿងក្នុងជាតកមួយចំនួនមកប្រែសម្រួលជាភាសាខ្មែរ ដោយរក្សាទុកភាសាបាលីខ្លះ។ ហើយអ្នកនិពន្ធខ្លះទៀត បានលើកយកប្រធានបទទាក់ទងនឹងកម្មផល កម្មពៀរ បាបនិងបុណ្យ ដែលជារឿងរ៉ាវជីវិតរបស់ព្រះពុទ្ធអង្គ កាលទ្រង់នៅជាពោធិសត្វឡើយ មករចនាតាក់តែងឡើងឱ្យស្របតាមគំនិតរបស់ខ្លួន គំនិតរបស់ប្រជារាស្ត្រខ្មែរ និងស្របតាមប្រពៃណីរបស់ស្រុកទេស តែផ្អែកលើមូលដ្ឋានទ្រឹស្ដីពុទ្ធសាសនាដែលខ្លួនកំពុងគោរព។ ស្នាដៃទាំងនោះចារលើស្លឹករឹតត្រូវអ្នកសិក្សាហៅថា«*អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ ឬធ្វើម*» ឬហៅម្យ៉ាងទៀតថា រឿងល្បែង ឬសាស្ត្រល្បែង។ ស្នាដៃសំខាន់ៗដែលយើងកេឃើញមានឈ្មោះអ្នកនិពន្ធនិងកាលបរិច្ឆេទ មួយចំនួនមានចំណងជើងនិងដំណើររឿងដូចគ្នាទាំងស្រុងនឹងរឿងក្នុងបញ្ញាសជាតកដូចជា៖

| | | |
|---|---|---|
| រឿង *សមុទ្ទឃោស* | ត្រូវនឹងជាតកទី១ | ឈ្មោះ *សមុទ្ទឃោស* |
| រឿង *ក្រុងសុភមិត្រ* | ត្រូវនឹងជាតកទី៩ | ឈ្មោះ *សុភមិត្ត* |
| រឿង *សព្វសិទ្ធ* | ត្រូវនឹងជាតកទី៤២ | ឈ្មោះ *សព្វសិទ្ធ* |
| រឿង ពុទ្ធិសែន | ត្រូវនឹងជាតកទី៣៩ | *ឈ្មោះ រថសេន* |

អំពីប្រលោមលោកពាក្យកាព្យ ជាទូទៅអ្នកនិពន្ធបានតាក់តែងតាមគំរូដំណែងនិពន្ធនៃរឿងក្នុងគម្ពីរសុត្តន្តបិដក ខុទ្ទកនិកាយជាតក ទសជាតក និងបញ្ញាសជាតកទាំងអស់។ ទោះបីជាស្នាដៃនោះមិនដកស្រង់ពីគម្ពីរទាំងបីខាងលើនេះក៏ដោយ ក៏យើងឃើញមានស្នាដៃភាគច្រើនមានលក្ខណៈសម្គាល់ក្នុងដំណែងនិពន្ធតាមបែបទសជាតកនោះ យើងឃើញមានពីរចំណុចដែលត្រូវនឹងលក្ខណៈរបស់ទសជាតក គឺ៖

-ដំណើររឿង និយាយពី «ដំណើរជីវិតរបស់ព្រះពុទ្ធអង្គ កាលទ្រង់នៅជាព្រះពោធិសត្វក្នុងជាតិផ្សេងៗ»។

-បញ្ចប់រឿង ដោយបញ្ជាក់ពីការ«*សជាតិ*» របស់តួអង្គនីមួយៗនាសម័យពុទ្ធកាល និង អ្នកនិពន្ធបានប្រើពាក្យថា«*លុះព្រះអង្គសម្ដែងធម៌ទេសនាចប់ហើយ ទើបទ្រង់ប្រជុំនូវជាតក ថា*»។ ដោយអ្នកនិពន្ធទាំងអស់ សុទ្ធតែបានបញ្ចូលចំណុចទាំងពីរនេះក្នុងស្នាដៃរបស់ខ្លួន នោះយើងអាចសន្និដ្ឋានបានថា លក្ខណៈរឿងនៅក្នុងទសជាតក គឺជាគំរូដំណែងនិពន្ធនៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិមយក្នុងសម័យកណ្ដាល។ អាចនិយាយបានថា អ្នកនិពន្ធបានអនុវត្តតាមគំរូនេះ ដើម្បីតម្រូវតាមលោកទស្សនៈសង្គមទាំងមូល ដែលកំពុងនិយមរឿងក្នុងទសជាតក ដែលជាគម្ពីរសំខាន់មួយក្នុងលទ្ធិពុទ្ធសាសនា។ មូលហេតុនេះហើយដែលនាំឱ្យមានការឯកភាពនៃដំណែងនិពន្ធសម្រាប់សម័យកាលទាំងមូល។

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម ចែកជាបីប្រភេទ គឺអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ អក្សរសិល្ប៍ពុទ្ធនិយមក្លាយ និង អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ(ផ្លូម)។ អក្សរសិល្ប៍ទាំងបីប្រភេទដែលគេកំណត់ហៅឈ្មោះនេះ ដោយគេសម្គាល់លើខ្លឹមសារនៃរឿង ដែលបង្ហាញពីឥទ្ធិពលពុទ្ធសាសនាតិចឬច្រើនតាមរយៈការពិពណ៌នារបស់អ្នកនិពន្ធនៅក្នុងរឿងនីមួយៗ សម្គាល់លើប្រភព និង អត្ថរូប នៃរឿង។

អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ ជារឿងដែលទទួលឥទ្ធិពលខ្លាំងបំផុតពីព្រះពុទ្ធសាសនា ហើយសំដៅយករឿងទាំង១០ ដែលថ្លែងពីអតីតប្រវត្តិរបស់ព្រះសក្យមុនីគោតមបរមសម្ពុទ្ធ ក្នុង១០ព្រះជាតិ មុនព្រះជាតិដែលបានត្រាស់ដឹង។ រឿងទាំង១០នោះសម្គាល់លើរឿងក្នុងស្នាដៃទសជាតក ដែលគេចាត់ទុកជាគម្ពីរដ៏សំខាន់នៃលទ្ធិព្រះពុទ្ធសាសនា ព្រោះរឿងទាំង១០នៃរឿងទសជាតកនេះមាននៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយជាតក ហើយបានលើកឡើងពីការតស៊ូរបស់ព្រះសម្មាសម្ពុទ្ធក្នុងពេលដែលព្រះអង្គយោនយកកំណើតជាតួអង្គពោធិសត្វ ក្នុងជាតិផ្សេងៗ ក្នុងការបំពេញបារមីដើម្បីបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ។

អក្សរសិល្ប៍ពុទ្ធនិយមក្លាយ ជារឿងដែលទទួលឥទ្ធិពលព្រះពុទ្ធសាសនាច្រើនបង្គួរដែរ តែឈ្មោះរឿងទាំងនោះមិនមាននៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយជាតក ទាំងអស់ទេ មានមួយចំនួនតូចប៉ុណ្ណោះ។រឿងខ្លះមានចំណងជើងរឿងដូចគ្នាទៅនឹងចំណងជើងជាតកនៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយជាតក តែខ្លឹមសាររឿងខុសគ្នាដោយអន្លើ។ រឿងមួយចំនួនទៀត ចំណងជើងរឿងខុសគ្នា តែខ្លឹមសាររឿងប្រហាក់ប្រហែលគ្នា។ រឿងមួយទៀត ចំណងរឿងក៏ដូចគ្នា និងខ្លឹមសាររឿងក៏ដូចគ្នា។ អក្សរសិល្ប៍ពុទ្ធនិយមក្លាយនេះ សំដៅយករឿងទាំង៥០ក្នុងបញ្ញាសជាតក។ តួអង្គនៅក្នុងរឿងអក្សរសិល្ប៍ពុទ្ធនិយមក្លាយនេះ មិនមែនជាតួអង្គព្រះពោធិសត្វ ដែលខំបំពេញបារមីដើម្បីត្រាស់ជាព្រះពុទ្ធនោះឡើយ គឺគ្រាន់ជាតួអង្គពោធិសត្វ ដែលខំកសាងអំពើជាកុសលផ្សេងៗជាដើម។

អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ ឬហៅពុទ្ធនិយមផ្លូម ជាស្នាដៃអក្សរសិល្ប៍មួយបែប ដែលពុំមែនជារឿងទសជាតក និង ពុំមែនជារឿងបញ្ញាសជាតក។ វាជាស្នាដៃអក្សរសិល្ប៍

ខ្មែរដែលកើតឡើងនៅសម័យកណ្តាល(លង្វែកនិងឧដុង្គ) ហើយទទួលឥទ្ធិពលពីលទ្ធិព្រះពុទ្ធសាសនាដែរ។ អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុនេះ ជាស្នាដៃរឿងនិពន្ធជាពាក្យកាព្យដោយកវីបណ្ឌិតខ្មែរក្នុងសម័យកណ្តាល ពិសេសក្នុងសតវត្សរ៍ទី១៧-១៩។ គេហៅស្នាដៃប្រភេទនេះថាជា *រឿងល្បែង ឬសាស្ត្រល្បែង* ក៏បានដែរ។ ស្នាដៃទាំងនោះនិពន្ធដោយអ្នកនិពន្ធខ្មែរ ហើយស្នាដៃភាគច្រើនមានឈ្មោះអ្នកនិពន្ធ មានកាលបរិច្ឆេទច្បាស់លាស់ ផ្តើមរឿងដោយមាននមស្ការថ្វាយបង្គំព្រះ ដោយប្រាប់ពីកាលបរិច្ឆេទ ប្រាប់ពីឈ្មោះអ្នកនិពន្ធ ប្រាប់ពីឈ្មោះបទកំណាព្យច្បាស់លាស់ ដូចជាបទពាក្យ៧ បទពាក្យ៨ បទពាក្យ៩ បទកុដុង្គ លីលា បទពំនោល បទបន្ទោកាក បទជ័យ បទមហាជ័យ បទរូស បទរាយ បទព្រហ្មគីតិ បទកាកគតិ។ ឯប្រធានបទរបស់ស្នាដៃរឿងអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុវិញ គឺនិយាយទាក់ទងនឹងកម្មពៀរពីបុព្វ ទាក់ទងនឹងការសាងអំពើល្អពីបុព្វនឹងផ្តល់ផលល្អក្នុងបច្ចុប្បន្ន ទាក់ទងនឹងការកសាងអំពើល្អផ្សេងៗ ទាក់ទងនឹងការធ្វើទាន។ល។ ប្រធានបទទាំងអស់នេះ ជាមូលដ្ឋានគំនិតរបស់អ្នកនិពន្ធក្នុងការនិពន្ធរឿងនីមួយៗ ដោយឈរលើគោលការណ៍ទ្រឹស្តីព្រះពុទ្ធសាសនា។ ជាមួយនេះ អ្នកនិពន្ធយកការរៀនប្រដៅផ្សេងៗរបស់បុព្វបុរសខ្មែរ ភ្ជាប់ជាមួយនឹងជីវិតព្រះពោធិសត្វ មកតាក់តែងកែច្នៃបញ្ចេញបញ្ចូលគំនិតទស្សនៈរបស់ខ្លួនឱ្យស្របនឹងផ្នត់គំនិតប្រពៃណីទំនៀមទម្លាប់របស់ប្រជាជនខ្មែរ ដើម្បីបណ្តុះស្មារតីឱ្យមនុស្សយល់ពីតម្លៃនៃការប្រព្រឹត្តអំពើល្អ ក៏ដូចជាការស្វែងយល់ឱ្យស៊ីជម្រៅពីតម្លៃនៃការអប់រំរបស់ពុទ្ធសាសនា និងការគោរពចំពោះពុទ្ធសាសនា។ *ផ្តើមរឿង* ដោយរំឭកគុណព្រះរតនត្រៃ រំឭកគុណគ្រូ គុណមាតាបិតា ប្រាប់ឈ្មោះអ្នកនិពន្ធ កាលបរិច្ឆេទ...។ *ខ្លឹមសាររឿង* ដំណាលពីជីវិតរបស់ពោធិសត្វកាលទ្រង់យោនយកកំណើតជាមនុស្សផ្សេងៗ។ *បញ្ចប់រឿង* ដោយបញ្ចាក់ពីការសជាតិនិង ការជួបជុំគ្រួសារ។

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមមានឥទ្ធិពលលើវិស័យហោរាស្ត្រ វិស័យនយោបាយ វិស័យច្បាប់ វិស័យសិល្បៈជាដើម។ ក្នុងវិស័យសិល្បៈ ត្រូវបានគេយកស្នាដៃរឿងទាំងនោះ ថតជាខ្សែភាពយន្ត លេងជាល្ខោនបាសាក់ ល្ខោននិយាយ ល្ខោនស្បែកពណ៌ ល្ខោនស្បែកតូច ចម្រៀង ជាចម្លាក់ ជាសិល្បៈសូនរូប ជាគំនូរ ជាដើម។ នៅតាមវត្តនីមួយៗ ឃើញមានរូបចម្លាក់ព្រះវេស្សន្តរបរាជរថ តាជូជកឡើងដើមឈើមានផ្លែពីរដេញខាំ តាជូជនដឹកដៃនាងអមិត្តតាបនា ព្រះសុវណ្ណសាម ព្រះមហោសថ នៅតាមទីធ្លាក្នុងវត្ត ដើម្បីបង្ហាញប្រាប់មនុស្សទូទៅបានយល់ដឹងពីសកម្មភាពនិងរូបរាងរបស់តួអង្គនីមួយៗ។ មិនតែប៉ុណ្ណោះនៅតាមវត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជាស្ទើរគ្រប់វត្តទាំងអស់សុទ្ធតែមានគំនូររឿងទសជាតក នៅតាមជញ្ជាំងវិហារ ឬជញ្ជាំងសាលាឆាន់ ដើម្បីបង្ហាញពីដំណើរជីវិតផ្សេងៗដែលតួអង្គនីមួយៗបានប្រព្រឹត្ត ដល់ពុទ្ធបរិស័ទបានយល់។

តាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម យើងឃើញមានបទពិសោធន៍សម្បូរបែបនៃការផ្ដល់យុត្តិធម៌ក្នុងសង្គម។ ការផ្ដល់យុត្តិធម៌ពីសម័យបុរាណ គឺផ្អែកលើព្រឹត្តិការណ៍ ឬស្ថានការណ៍ ការធ្លាប់អនុវត្ត តថភាពពិត ហេតុការណ៍ពិតជាក់ស្ដែង និងការឱ្យតម្លៃលើហេតុផល ដើម្បីវិនិច្ឆ័យទោស។ មនុស្សរស់នៅក្នុងសង្គមតែងត្រូវការយុត្តិធម៌ និងការទទួលបានយុត្តិធម៌ វាជាបញ្ហាដ៏ស្មុគស្មាញបំផុតសម្រាប់បុគ្គល និងសង្គមនីមួយៗ។ លក្ខណៈនៃការផ្ដល់យុត្តិធម៌ និងទទួលបានយុត្តិធម៌ មានបែបផែនឬវិធីផ្សេងៗពីគ្នាទៅតាមសម័យកាលនីមួយៗ ឧទាហរណ៍នៅក្នុងស្នាដៃពុទ្ធនិមជាច្រើន ពិសេសនៅក្នុងរឿង*មហោសថ* យើងឃើញការផ្ដល់យុត្តិធម៌មានតាមរបៀបផ្សេងៗគ្នាទៅតាមបញ្ហាដែលកើតមានឡើង។ មិនត្រឹមតែរបៀបផ្ដល់យុត្តិធម៌ប៉ុណ្ណោះទេ អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមនេះ បានបង្ហាញពីទសពិធរាជ-ធម៌ ដែលមានចែងនៅក្នុងគតិសាសនារបស់ខ្មែរយើង ហើយត្រូវខ្មែរយើងចាត់ទុកដូចជាវិន័យ ឬច្បាប់សម្រាប់ទូន្មាន និងបង្ហាញពីគុណសម្បត្តិ ព្រមទាំងបុគ្គលិកលក្ខណៈល្អនៃបុគ្គលដែលអ្នក គ្រប់គ្រងក្នុងសង្គម។ ទសពិធរាជធម៌ដែលបានបង្ហាញក្នុងរឿងវេស្សន្តរនោះ គឺមាន៖ ១-*ទាន* ការធ្វើអំណោយ, ២-*សីល* ការរក្សាសីល៥ជានិច្ច ឬរក្សាសីល១០ មួយដងមួយកាល, ៣-*បរិច្ចាគ* ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ, ៤-*អាជ្ជវៈ* មានសេចក្ដីត្រង់, ៥-*មទ្ទវៈ* មានសេចក្ដីទន់ភ្លន់ស្លូតសុភាពរាបសា, ៦-*តបៈ* ការកាន់ឧបោសថសីលតាមកាលកំណត់ម្ដងៗ, ៧-*អក្កោធនៈ* មិនកម្ដៅក្រហាយអ្នកដទៃ, ៨-*អវិហឹសា* មិនបៀតបៀនអ្នកដទៃ, ៩-*ខន្តិ* មានសេចក្ដីអត់ធន់, ១០-*អវិរោធនៈ* មិនបំពានលើធម៌លើច្បាប់។ តាមរយៈខ្លឹមសារនិងបទពិសោធន៍ដែលបានបង្ហាញក្នុងរឿងវេស្សន្តរនេះ យើងយល់ថា បើអ្នកមានអំណាចគ្រប់គ្រងផ្ទៃ ទោះអំណាចនីតិបញ្ញត្តិក្ដី នីតិប្រតិបត្តិក្ដី និងតុលាការក្ដី បានតម្កល់ខ្លួននៅក្នុងទសពិធរាជធម៌ទាំង១០នេះ លោកអាចត្រូវចាត់ទុកថា ជាបុគ្គល ជាថ្នាក់ដឹកនាំដ៏ល្អ ដែលប្រកបដោយធម៌។

នៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមក៏បានបង្ហាញពីរាជវសតីធម៌ ជាពិសេសក្នុងរឿង*វិធុរបណ្ឌិត* ដំណើររឿងផ្នែកខ្លះបានបង្កប់នូវរាជវសតីធម៌ឬច្បាប់សម្រាប់អប់រំមនុស្សក្នុងរាជត្រកូល ក៏ដូចជាច្បាប់ឬវិន័យ សម្រាប់អប់រំបុគ្គលជាអ្នករាជការនៅក្នុងប្រទេសទាំងមូលដែរ។ ទាំងនោះជាលក្ខណៈច្បាប់ដែលជះឥទ្ធិពលមកលើវិស័យច្បាប់រហូតបច្ចុប្បន្ន។ ទោះបីលក្ខណៈ ច្បាប់នៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមពុំមានលក្ខណៈពេញលេញក៏ដោយ ក៏ច្បាប់ទាំងនោះជាគន្លងមួយដែលជាមូលដ្ឋានខ្លះនាំឱ្យលេចឡើងនូវច្បាប់សម្រាប់អប់រំដល់រាជសេវក(មន្ត្រីរាជ)ប្រតិបត្តិដែរ។ ប្រសិនមន្ត្រីរាជការ ឬបុគ្គលជាអ្នកនៅក្រោមបង្គាប់ ក្រោមការគ្រប់ គ្រង បានប្រព្រឹត្តតាមរាជវសតីធម៌ ដែលជាច្បាប់ឬជាវិន័យនេះ បុគ្គល

នោះនឹងទទួលបាននូវសេចក្តីចម្រើនពុំខាន។ អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម បានឆ្លុះបញ្ចាំងពីតម្លៃពុទ្ធិដ៏ទូលំទូលាយក្នុងការដោះស្រាយបញ្ហាទាំងឡាយប្រកបដោយសុទិដ្ឋិ ឆ្លើយតបនឹងព្រះមហាក្សត្រនិងចំពោះមនុស្សទូទៅ ថែមទាំងបង្ហាញពីភាពកតញ្ញូចំពោះមនុស្សដែលធ្លាប់មានគុណចំពោះខ្លួន និងបង្ហាញពីការប្រឹងប្រែងរបស់ខ្លួនឯងយ៉ាងស្វាហាប់ ដែលជាបទពិសោធន៍ ជាគំរូ ជាការអប់រំដ៏ល្អ សម្រាប់មនុស្សទូទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ។ ខ្លឹមសារក្នុងស្នាដៃបង្ហាញពីទង្វើអហិង្សា គំនិតអហិង្សា មិនបៀតបៀនអ្នកដទៃ ចង់បានសន្តិភាពក្នុងសង្គម។ ការបណ្តុះគំនិតសន្តិភាពតាមរយៈតួអង្គក្នុងរឿងពុទ្ធនិយមនេះ វាជាបទពិសោធន៍ ជាការទូន្មាន និងជាគំរូដល់មនុស្សគ្រប់គ្នា សម្រាប់អនុវត្តក្នុងសង្គមគ្រួសារឬសង្គមជាតិទាំងមូល នោះនឹងទទួលបាននូវភាពសុខដុម និងសេចក្តីចម្រើនមិនខាន។

សរុបមក ស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម ជាគំរូមួយក្នុងការអប់រំមនុស្សឱ្យស្រឡាញ់សន្តិភាព ឱ្យស្រឡាញ់អំពើល្អ ឱ្យមានការព្យាយាម ឱ្យចេះស្គាល់គុណ ឱ្យខ្លាចបាប ឱ្យចេះប្រើបញ្ញា ឱ្យចេះពិចារណាលើហេតុនិងផល ជាដើម។ ដូច្នេះទើបគេចាត់ទុកអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមនេះ ជាស្នាដៃអក្សរសិល្ប៍តន្តីរបស់ខ្មែរមួយ ផ្នែកខាងពុទ្ធសាសនា។ ស្នាដៃទាំងនេះ មានតម្លៃមហាសាល មានប្រយោជន៍យ៉ាងជ្រាលជ្រៅ នៅក្នុងមជ្ឈដ្ឋានអ្នកសិក្សាជាតិនិងសង្គមមនុស្សទូទៅ និង ជាខឿនយ៉ាងរឹងមាំរបស់វប្បធម៌អរិយធម៌ខ្មែរយើង។

# Summary

Bhramanism and Buddhism derived from India. These two religions are the vital elements for building the Khmer culture. Khmer ancestors believed in these religions with mixing with her old culture by revising their characteristcs in accordance with Khmer citizen' concepts. In these reasons, the Khmer empire gained the great achivements from time to time, especillly in the Angkorian period and the next. These religions brought Pali and Sangkrit languages and mixed them with Khmer langauge for the Khmer empire. The influeences of these religions are deeply rooted in the sperits of Khmer citizen and brought not only the beliefs but also literatures.The literature emerged apprarently has been the novel of Ramayana which influenced by the influence of Bhramanism. This literature was recognized as the noble one in the Angkorian period. After the recession of Bhramanist influence, Khmer people changed their mind to belive in Buddhism.

Buddhism transformed literature from Khmer literature into Buddhist literature. This literature was the important work of Khmer literature which originated since the middle age(the period of Longvek and Udong)and has been still popular to the present day.

In the works of literature have been full of knowledge on human beings, culture, tradition, custom and relationship between human beings and human beings etc. Besides that it reflects the historical and social values. These heritages of culture and civilization were kept in the spirits of every Khmer citizen and always reminded them of the ancestors' great social works which were memorably national spirits. Morever, it made us to love, protect these great cultural heritages for the next generation.

Khmer Literature in Buddhism is the ancient novel influenced by Buddhism which helped readers, listeners, audiences to receive good values of education, different experiences and non-violence building as well as providing pleasure which reduced stress and escaped from suffering in daily life. In the middle age was the period which the Kingdom of Cambodia faced a lots of problems(such as invasion war from the neighboring countries, civil war,starvation ect.)

Khmer Literature in Buddhism has player the vital roles in human education to understand the reasons of real life that is concerning with the patient to problems and strengthening the spirits of people to be strong and lived in the real situation to resist the foreign invasive enemies who intented to invade Cambodian territory.

Khmer Literature in Buddhism has been recognized and named when Khmer citizen believed deeply in Theravada Buddhism and when Theravada Buddhism was propagated in Cambodia in the middle age.

The determination of name above is in accordance with Khmer Scholars went to study at Sri Lanka. Aftet they come back home, they translated the legends from

Pali language into native language and wrote the different novels in accordance with their perspectives and Khmer concepts.

After that time, Khmer Literature in Buddhism received the great intention from Khmer Citizen and there were a number of writers who wrote this kind of literature. Monks used the legends of Khmer Literature in Buddhism to preach for different religious cerymonies. In addition, monks inscriped Khmer Literature in Buddhism on the Satra(documents written on the Ret leaf) and oral recopying from time to time for keeping in every temples for monks and pupils to study. Scholars and Reseachers called Khmer Literature in Buddhism by diferent names such as: Religious legends, Religious Literature, Buddhist Literature and Khmer Literature in Buddhism, or Tipitaka(three baskets, basket of Discipline, Discources and Doctrine) related to the kind of Buddhist stories ect.

The Southeast Asian countries which respected Theravada Buddhism such as Cambodia, Myanma, Lao and Thailand and so on all having Literature in Buddhism just different with each other by revising and changing the forms in accordance with the authors' perspectives, traditions and custums of each countries respectively.

Khmer Literature in Buddhism had its sources from Tipitaka( Sutta Pitaka Khuddaka Nikaya Jataka) and existed in the Khmer territory in the middle age((the period of Longvek and Udong in 15-19 century) in the time that Khmer citizen strongly practiced Theravada Buddhism. The reasons that shown Khmer citizen believed in Theravada Buddhism are: (1) Buddhism has been based on the subjective principle, (2) Buddhist teachings has been in accordance with Khmer citizen' character, (3)Buddhism has been mixed with Khmer culture, (4) Buddism has been interrelated with geography called geo-religion (5) Buddhism has been the noble truth. Buddhist teachings are the best way of good givenance, social works, and rule of law, that is, these teachings can be applied in all fields of social lives. On the other hand, Buddhist teachings are the principle of non-violence, peace and world theories for humanity regardless of color, rich, poor and social status.

The edcucation of Khmer citizen at that time was dependent on the Buddhist temples because Buddhist temples were the schools for building all knowledges for Khmer citizen. Monks played the important roles for teaching all aspects of knowledges such as algebra, literature,medical care, law, morality, art and professionals, especially Buddhist knowledges. Due to the Buddhist temples were the centers of knowledges, that why every families at that time sent their childrent to the temples for receiving education. Thus, Monks and temple-school pupils were Satra inscribers and Satras were distributed to all Buddhist temples in Khmer territory for the interests of education.

Khmer Literature has evolved through the big age of history, evolution of regime and the change of their beliefs in each age. In the Angkorian Period, Khmer culture and Civilization greatly advanced and so do the Literature, but they have falled down when Khmer empire was invaded by the neighboring countries.

The Angkorean Literature was even influenced by doctrines of Veda, Bhramanism, and Buddhism continuously, but it still maintained Khmer's form, characteristics having seen in the legend of Ramayana which wrote as the poem thar have tendency to Bhramanism was respected by Khmer citizen at that time.

After receiving the great achievements, Khmer literature started disappearing between 15th-16th century because of the darkness of history of foreign aggressions. In the 17th century, the works of literature appeared again and Pali langauge which used in the Theravada Buddhism appeared instead of Sankrit Langauge that was recognized as the langauge of the wise men as return and Buddhist teachings and literature was propagated rapidly in the spirits of Khmer citizen. At that time, the works of simple literature existed such as legends, short true stories leading residents listened and understood easily.

Between 18th-19th century, due to the social upheaval and aggressive war, the dissemination of literture was not comprehensively propagated yet. On the othe hand, because of method for poetic writting and miscelliness words had no unity, that why Khmer wise men tried to uplift the situation of that recession such as establishing the method of poetic writting and method of miscelliness word to be correct, providing the opportunity to study Pali langauge, translating Buddhist texts and tales of the former birth of Buddha from Pali langauge into Khmer langauge.

After these achivements were simplified, residents could read and talk from place to place until these tales became the story of popular literature for common residents. For the next, some of the achievements of literatures especailly the materpiece as poetic novels which were relevant to Budhhist teachings appeared. They were inscribered in the Ret leves(leves like Palm leaf for writting) and transcribed and distributed from one person to one person in order to read for the whole villages.

The authors were well-known such as : Ukgna Kosatippadikeou (wrote the Suphamith story), Ukgna Khlang Nong (wrote the law, proverb, story of LOKKANEYA tale, BUSARISA, PHOKKULLAKUMA story), UKGNA SANTHVOHAMUK (wrote the DEVINDA story, LBAEK CHACHAK(wolf joke), TUMTEAV story(before TUMTEAV written by Ven. Som) VISESDONG, LBEK OK(vulture joke), LBEKCHUCH and TRI(short joke about woven fish-trap and fish), LBEK CHO CHOK(short joke about Bhraman beggar CHO CHOK), His Majesty King Ong Doung wrote about story of CHOMPA TONG, KAKEI(story of a beautiful but unfaithful woman named) CHBAP SRI(woman law), the story of PREAH MOHAVESSANDA(miscelliness words etc.)

The achievements were found and affirmed the achievements in the middle age only the works in the 17th-19th. There were lots of Scholars agreed with each other that 17th century was the new origin of Khmer literature. If we deeply concentrate on these achievements in that new origin, we will realise that Khmer literature evolved one new step both the method of writting and popularity of these

achievements. This evolution was extremely related to the enfluences of religions, Bhramanism and Mohayana Buddhism, were changed by citizen's beliefs and bevieved in Theravada Buddhism instead that was brought from Sri Langka.

Theravada Buddhism at that time was strongly flourished and influenced in the whole social lives as well as symbolizing on the literature. For the views of sholars and researcher, they chose Pali language for using in the Theravada Buddhism and stoped usung Sankrit language that was used in the Bhramanism.

Khmer writters at that time decorated Pali words mixing with Khmer words to become the poetic words and those poetic words were sweetly pretty. We observed that Pali and Khmer Poetic phrases had romantic characteristics supporting vinakatha that was ablute contrary to Sankrit and Khmer poetic phrases in the Angkorian period which was in accordance with the meaning of brave tale.

The middle age was the time that Khmer litetature in Buddhism originated surely. It was related to the factors of social problems that made terrible situations, people faced difficulties, especially it was concerning with accepting Theravada Buddhism.Theravada Buddhism educated people to believe in the cause and effect. This religion was the roots having literature writters in the middle age, especially in the Udong period until to the present day. In the history of Khmer literature, we found that in the middle age evolved about methodology devided into two phases differently as fellow:

First Phase: From 16th-17th century, we found only the miscelliness texts for preaching sermon, poetic words for telling a story and romantically poetic texts. The well-known authors of this phase are:

-The group of Khmer authors wrote about the 50 tales of the former births of Buddha as the misscelliness words during the 1457-1657.

-Author Pong wrote about the LBAEK(fiction or short story made up as a joke) as the misseclliness words named"LBAEK ANGKOR" in the 1609 that described about the story of building the Angkor.

-Preah Rajja Samphea wrote about romantic poems such as poem titled" Hemman Meas-Cold Gold" in 1629 and poem titled" Kap Nireass-Dispair Poem" in 1660.

-The poems of Preah Rajja Samphea were the poems showing about the author's sentiment to the girls and the nature that the author was interested in it.

Second Phase: From 18th century, we found the establishing the workd of novel as rhyme. In general, we saw that the symbolizing of literatures at that time were based on foundation of religious scripture, especially Sutta Pitaka Khuddaka Nikaya Moha Nipata(Tipitaka) and scripture of 50 tales of the former births of Buddha were become the sources of symbolizing of the title and symbolizing of the novel process of Khmer authors.

During the 18th-19th century, some of Khmer authors quoted some story from tales to translate into Khmer language by keeping some original Pali language. Some

in Buddhism due to the these ten stories of Dassa Jâtaka consisted of Sutta Pitaka Khuddaka Nikaya Jâtaka and talking about the patients of Lord Buddha when he had rebirth when he was the one destined to obtain enlightenment in different births in the past.

The fake Buddhist Literature has been the story which influenced by Buddhism, but the titles of the stories had no in the Sutta Pitaka Khuddaka Nikaya Jâtaka so much, but a little. The titles of some stories were the same with the title of Jâtaka in Sutta Pitaka Khuddaka Nikaya Jâtaka, but the meaning of stories were different in some parts. The titles of the other stories were also the same and so do the meaning. This fake Buddhist Literature refered to the scripture of 50 tales of the former births of Buddha. The actors of the fake Buddhist Literature were not the one destined to obtain enlightenment , they were only the one who tried to do the wholesome.

The absolutely transformed Buddhist Literature was the work of one kind of literature not Dassa Jâtaka and 50 tales of the former births of Buddha. It is the work of Khmer Literature originated in the middle age(Long Vek and Udong) and influenced from Buddhism. This absolutely transformed Buddhist Literature is the work of poetic writings by Khmer writters in the middle age,especially in the $17^{th}$-$19^{th}$ century.

These works were called as Roeurng Lbeng or Sastra Lbeng. They were written by Khmer scholars and most of these achievements having the real name of scholars, time. The beginings of these works were begun by the homage to the Lord Buddha, the exalted one, by telling the schedule, name of the authors, title of the poems particularly such as seven rhyme poems, eight rhyme poems, nine rhyme poems, name of a Khmer rhyme scheme, rhyme of sayings, victorious meter , Bantokak meter, Mohavichey meter, Rous meter, Reaya meter, Phramakit meter(poem having a meter consisting of four feet per stanza and four syllables per foot), Kakati meter(a type of meter in Khmer poetry in which there are four syllables in each line, its rhythm is likened to a crow hopping).

While the topics of works of The absolutely transformed Buddhist Literature talk about the former misfortune, bad and luck that were related to doing good in the past and receive good results in the present day such as charity etc. These topics are the sources of ideas of the authors for writing each story basing on the Buddhist approaches.

In this sense, the authors raised the ancestor's education to mixe with the life of one destined to become Buddha for decorating with their ideas in accordance with Khmer traditions, customs to build the spirits for haman beings to understand the values of good deeds as well as to understand deeply about the education of Buddhist teachings and the respect to Buddhism.

The introduction recalled a favor to the Triple gems, parents, teachers, authors, schedule.... The body tell about the life of one destined to become Buddha when he

was born in different births in haman planet. The conclusion confirms about the rebirths and unity of family.

Khmer Literature in Buddhism has influenced on the field of astrology, politics, law and art and so on. In the field of arts, the achievements of stories were used for the firms, performance of Lkhon Basak, Lkhon Niyaya, Lkhon Sbek Por, Lkhon Sbek Toch, songs, sculpture, art of model of a wax statue, drawings, ect.

Every Buddhist temple was carved the picture of Vessandor driving a cart, Beggar Cho Châk climing the tree and was bitted by the dogs, Beggar Cho Châk went hand in hand with his wife (Amittâtapana), Suvannasam sage, Mahosath sage in the compound of the temples in order to tell the general people about the activities and image of every actors. Moreover, in nearly every temples in the Kingdom of Cambodia were full of the pictures of Dassa Jâtaka carving on the wall of temple or wall of dining hall for showing the different lives of each actors commited to the Buddhist people.

By Khmer Literature in Buddhism was well experienced to provide the socail justice. The provision of socail justice in the ancient time was based on the real situations(de facto)were used to be applied, reality, real facts or issues and the values of reason for judgements.

Khmer people always need justice while receiving the justice has been very complicate for individual and society. The characteristics of receiving and provising the social justice consist of different ways according to every circumstance, for instance in the works of many Buddhist literatures, especially in the Mahosath legends. We saw that the social provison consisted of number of ways according to the issues happened. In addition, Khmer Literature in Buddhism not only the methods to provide social justices but also cited about the tenfold qualification of the king or tenfold conducts of the king having in doctrine of our Khmer religion and were recognized as the discipline or law for training and they showed the qualification as well as moral conducts of the social rulers.

The tenfold qualification of the king cited in the Vessandor Jâtaka are: 1-Charity, 2-Morality(five , eight or ten precepts), 3-Saccrifice,4-Honesty, 5-Softness, 6-Austerity, 7-Calmness, 8-Peacefullness, 9-Patience, 10-Respect for the law.

By the meanings and experiences existed in the Vessandor Jâtaka, we understand that, if the state rulers in the executive, legislative and judicial branches respect and perform the tenfold of the king, then he or she will be the good leader or rulers with Dhamma.

In the works of Khmer Literature in Buddhism also revealed about Rajja Savati Dhamma(the King's law or Dhamma), especially in the story of Vithu Pandith. Some matters buried in the ground of Vasati Dhamma or law for educationg persons in the royal families look like law or discipline for educationg public officails in the whole country. These are the characteristics of law that influence on the aspect of law